មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (អង្គការសេដាក)

ផ្ទះលេខ ១១៩ ផ្លូវ ២៥៧ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ

ប្រអប់សំបុត្រលេខ ១១១៨ ទូរស័ព្ទ: ៨៥៥-២៣-៨៨០ ៩១៦ ទូរសារ: ៨៥៥-២៣-៨៨៥ ១៤៦

# សេចក្តីប្រកាសព័ត៌មាន

*Released June 14, 2010*

## ការរើសសំរាំងពូជស្រូវ គឺជាកត្តាសំខាន់បំផុត ដើម្បីអោយកសិករទទួលបានទិន្នផលស្រូវខ្ពស់ នៅរដូវវស្សាឆ្នាំនេះ

មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៏កសិកម្មកម្ពុជា (អង្គការសេដាក) ជាអង្គការមិនមែនរដ្ឋាភិបាលខ្មែរ ឯករាជ្យ មិនស្វែងរកកំរៃផលប្រយោជន៏បុគ្គល និងមិនពាក់ព័ន្ធគណបក្សនយោបាយ។ សេដាក បានត្រូវបង្កើតឡើងនៅឆ្នាំ ១៩៩៧ ក្នុងគោលបំណងពង្រឹងសមត្ថភាព និងភាពជាម្ចាស់របស់កសិករ ក្នុងការកែលំអគុណភាពជីវិតរបស់ខ្លួន និងចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍន៏សង្គម”។

ខណៈដែលប្រជាកសិករខ្មែរបាននិងកំពុងតែមមាញឹកជាមួយនឹងការសាបព្រោះ ធ្វើស្រែនៅរដូវវស្សាឆ្នាំនេះ មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៏កសិកម្មកម្ពុជា (សេដាក) សង្កេតឃើញថា កន្លងមកប្រជាកសិករខ្មែរតែងតែធ្វើការរក្សាទុកពូជស្រូវនៅរដូវច្រូតកាត់សម្រាប់ធ្វើការដាំដុះនៅរដូវបន្ទាប់ ប៉ុន្តែនៅមិនទាន់បានយកចិត្តទុកដាក់នៅឡើយទៅលើ **ការរើសសំរាំងពូជស្រូវ** នៅមុនពេលយកទៅសាបឬដាំដុះ។

លោកបណ្ឌិត យ៉ង សាំងកុមារ ប្រធានអង្គការសេដាកពន្យល់ថា ការរើសសំរាំងពូជស្រូវមុនពេលដាំដុះ គឺជាកត្តាសំខាន់បំផុតចំពោះកសិករ ដើម្បីទទួលបានទិន្នផលស្រូវខ្ពស់ និងលក់ស្រូវបានតម្លៃថ្លៃ។ លោកបណ្ឌិតបន្តថា ដើម្បីធ្វើការរើសសំរាំងពូជស្រូវគឺត្រូវរើសចេញនូវគ្រាប់ស្រូវ ដែលមិនមានគ្រាប់ពេញ និងសុទ្ធល្អ មានស្នាមប្រេះ កំពិតកំពក ឬមានជំងឺ ដោយរើសយកតែគ្រាប់ស្រូវដែលមានគ្រាប់ពេញ និងសុទ្ធល្អយកទៅសាបនិងធ្វើការដាំដុះ។” កសិករត្រូវការចំណាយពេលតែ ២ ឬ ៣ថ្ងៃតែប៉ុណ្ណោះ ដើម្បីធ្វើការរើសសំរាំងពូជស្រូវមុននឹងធ្វើការដាំដុះ ប៉ុន្តែការរើសសំរាំងពូជស្រូវបានល្អនេះ នាំឱ្យកសិករទទួលបានទិន្នផលស្រូវខ្ពស់ពី ១០-៣០% និងលក់បានតម្លៃថ្លៃ ” នេះបើតាមប្រសាសន៏របស់បណ្ឌិត យ៉ង សាំងកុមារ ប្រធានអង្គការសេដាក។

ផ្អែកតាមបទពិសោធន៏ និងការកើនឡើងនូវទិន្នផល មណ្ឌលសិក្សានិងអភិវឌ្ឍន៏កសិកម្មកម្ពុជា (សេដាក) សូម**ធ្វើការអំពាវនាវ** ដល់ប្រជាកសិករដែលបាននិងកំពុងសហការជាមួយអង្គការសេដាក ក៏ដូចជាស្ថាប័នពាក់ព័ន្ធដែលធ្វើការផ្នែកកសិកម្មទាំងអស់ ធ្វើការជម្រុញការរើសសំរាំងពូជស្រូវដោយយកតែស្រូវ ដែលមានគ្រាប់ពេញ និងសុទ្ធល្អយកទៅសាប និងដាំដុះនៅរដូវវស្សាឆ្នាំនេះ។

**ទំនាក់ទំនង:** សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង លោក ហ៊ឹម ខទៀត: ០១៦ ៩៧៥ ៧១៣

**Centre d'Etude et de Développement Agricole Cambodgien (CEDAC)**

No 119 St. 257 Sangkat Teuk Laak 1, Khan Toul Kork, Phnom Penh - Cambodia
P.O.Box: 118, Tel.: 855-23-880 916, Fax: 855-23-885-146, E-mail: cedac@online.com.kh

លោកអ្នក
គួរយល់ដឹង

# ការរើសសំរាំងពូជស្រូវគឺជាកត្តាសំខាន់បំផុត ឱ្យកសិករទទួលបានទិន្នផលស្រូវខ្ពស់ឆ្នាំនេះ



មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (អង្គការសេដាក) ជាអង្គការមិនមែនរដ្ឋាភិបាលខ្មែរ ជាការមិនរកប្រាក់ចំណេញ ដែលប្រកាន់ខ្ជាប់ និងមិនកាន់ជើងខាងបក្សនយោបាយ ។ សេដាក បានត្រូវបង្កើតឡើងនៅឆ្នាំ១៩៩៧ ក្នុងគោលបំណងលើកកម្ពស់ សមត្ថភាព និងភាពជាម្ចាស់របស់កសិករ ក្នុងការកែលម្អគុណភាពជីវិតរបស់ខ្លួន និងចូលរួមអភិវឌ្ឍសហគមន៍ ។

ខណៈដែលប្រជាកសិករខ្មែរយើងកំពុងតែជួបការលំបាកនឹងការខ្វះខាត ព្រោះថ្លៃស្រូវនៅថ្លៃក្នុងឆ្នាំនេះ មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (សេដាក) សង្កេតឃើញថា ក្នុងរយៈពេលកន្លងមក ប្រជាកសិករខ្មែរ ធ្វើការជ្រើសរើសពូជស្រូវសំរាប់ដាំដុះ ភាគ សំរាប់ធ្វើការដាំដុះនៅរដូវបន្ទាប់ ប៉ុន្តែនៅមិនទាន់បានយកចិត្តទុកដាក់នៅឡើយ ទៅលើការរើសសំរាំងពូជស្រូវមុននឹងយកទៅសាប ឬដាំដុះ ។

លោកបណ្ឌិតយ៉ាង សាំងកុមារ ប្រធានអង្គការសេដាកបានឲ្យដឹងថា ការរើសសំរាំងពូជស្រូវមុននឹងដាំដុះ គឺជាកត្តាសំខាន់បំផុតសំរាប់កសិករ ដើម្បីទទួលបានទិន្នផលស្រូវខ្ពស់ និងលក់ស្រូវបានតំលៃថ្លៃ ។ លោកបណ្ឌិតបន្តថា ដើម្បីធ្វើការរើសសំរាំងពូជស្រូវ គឺត្រូវរើសចេញនូវគ្រាប់ស្រូវ ដែលមិនមានគ្រាប់ពេញ និងស្អុយ មានស្នាមប្រេះ ប្រហោង ស្កក ឬរាងខុស ដោយរើសយកតែគ្រាប់ស្រូវដែលមានគ្រាប់ពេញ និងស្អាត យកទៅសាប និងធ្វើការដាំដុះ ។ កសិករត្រូវការចំណាយពេលតែមួយ ឬពីរថ្ងៃប៉ុណ្ណោះ ដើម្បីធ្វើការរើសសំរាំងពូជស្រូវមុននឹងធ្វើការដាំដុះ ប៉ុន្តែការរើសសំរាំងពូជស្រូវមួយនេះ អាចឱ្យកសិករទទួលបានទិន្នផលស្រូវខ្ពស់ពី១០-៣០% និងលក់បានតំលៃថ្លៃ ។ នេះបើតាមប្រសាសន៍របស់លោកបណ្ឌិតយ៉ាង សាំងកុមារ ប្រធានអង្គការសេដាក ។

ផ្អែកតាមបទពិសោធន៍ និងការពិសោធន៍ផ្ទាល់ មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (សេដាក) សូមធ្វើការផ្សព្វផ្សាយដល់ប្រជាកសិករដែលបានធ្វើការជាដៃគូជាមួយអង្គការសេដាក ក៏ដូចជាអ្នកដែលធ្វើការផ្នែកកសិកម្មទាំងអស់ ធ្វើការជំរុញការរើសសំរាំងពូជស្រូវយកតែស្រូវដែលមានគ្រាប់ពេញ និងស្អាតយកទៅសាប និងដាំដុះនៅរដូវវស្សាឆ្នាំនេះ ។ សំរាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងលោក ជឿន ទូរស័ព្ទ : ០១៦ ៨៧៤ ៧១៣ ។